( ២ )

# អនុក្រឹត្យស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ: ១៧ អនក្រ.បក

ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ [illegible] អនក្រ.បក

ក្រសួងកសិកម្ម
ចុះបញ្ជី
ថ្ងៃទី
លេខ 934
ថ្ងៃទី 18-4-2000
ហត្ថលេខា

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០០

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់ការរៀបចំឈ្មោះភារកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភារកិច្ច បេសកកម្មរបស់ក្រសួង និងមុខការនៃឈ្មោះអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងនាយកដ្ឋានខាង នៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## បេសកកម្ម និង ភារកិច្ច

មាត្រា ២.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរាជរដ្ឋាភិបាល ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រង លើវិស័យកសិកម្ម នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំ និងដាក់អោយដំណើរការ នយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងគោលបំណងកែលំអកំរិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ
- ចូលរួមក្នុងការរៀបចំគោលនយោបាយកែទំរង់ និងប្រើប្រាស់ដីធ្លី
- តំរង់ទិស និង ធ្វើផែនការ អភិវឌ្ឍន៍វិស័យកសិកម្មគ្រប់ផ្នែក
- សំរបសំរួល តាមដាន និងវាយតំលៃ លើការអនុវត្តនយោបាយ និង សកម្មភាពអភិវឌ្ឍន៍កសិកម្ម
- តាមដានការវិវត្តនៃធនធានធម្មជាតិ របស់វិស័យកសិកម្ម និងសំរួលដល់ការធ្វើអាជីវកម្មធនធានធម្មជាតិ ទាំងនោះ ដើម្បីបំពេញ តំរូវការរបស់ប្រទេសជាតិ និងគោរពលំនឹងអេកូឡូស៊ី
- កំណត់បទប្បញ្ញត្តិ ក្នុងការគ្រប់គ្រង ថែរក្សា ការពារ ធនធានធម្មជាតិរបស់វិស័យកសិកម្ម និងតាមដានការអនុវត្ត
- វាយតំលៃ និងបណ្តុះបណ្តាលធនធានមនុស្ស សំរាប់ចូលរួមក្នុងការអភិវឌ្ឍន៍កសិកម្ម ដោយលើកកំពស់កំរិត យល់ដឹងបច្ចេកទេស និង បង្កលក្ខណៈប្រើប្រាស់ធនធាននេះ អោយមានប្រសិទ្ធភាព
- ផ្តល់ការគាំទ្រ និងការណែនាំបច្ចេកទេសជាចាំបាច់ដល់កសិករ ដើម្បីកែលំអផលិតកម្ម និងផលិតភាពកសិកម្ម
- កំណត់គោលការណ៍និងតាមដានការអនុវត្ត លើកកំពស់ និងកែលំអដំណើរប្រព្រឹត្តទៅរបស់អង្គការ វិជ្ជាជីវៈ សមាគមនានា ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម
- សិក្សាស្រាវជ្រាវ និង ផ្សព្វផ្សាយអំពីវិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ច ក្នុងវិស័យកសិកម្មគ្រប់ផ្នែក
- ណែនាំការងារអភិវឌ្ឍន៍ដី និង ការកែលំអគុណភាពដីនិងប្រើប្រាស់ដីកសិកម្ម ពូជរុក្ខជាតិ ពូជសត្វ ជីគីមី និងថ្នាំកសិកម្មអោយបានសមស្របទៅតាមលក្ខណៈភូមិសាស្ត្រ អាកាសធាតុរបស់តំបន់ ដើម្បីធានាបានទិន្នផលខ្ពស់ និង រក្សាគុណភាពបរិស្ថាន ធម្មជាតិ
- ធ្វើសហការជាតិ និង សហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍ វិស័យកសិកម្មគ្រប់ផ្នែក

- ចូលរួមក្នុងការជំរុញ និងលើកកំពស់ ការវិនិយោគ ការនាំចេញផលិតផលកសិកម្ម និងម្ហូបអាហារ
- ចូលរួមអនុវត្តការងារពាក់ព័ន្ធ នឹងអាងទន្លេមេគង្គ ស្របតាមភារកិច្ចរបស់ក្រសួង
- ចូលរួមកសាងគោលនយោបាយថ្លៃ និងរកទីផ្សារសំរាប់ផលិតផលកសិកម្ម
- ប្រមូលថវិកាបង់ចូលរដ្ឋ ឬសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការប្រមូលចូលរដ្ឋ
- អនុវត្តកិច្ចការផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

មាត្រា ៤ .-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានរចនាសម្ព័ន្ធដូចតទៅ :

ក-អង្គភាពថ្នាក់កណ្តាល :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋាន នៃក្រសួង

អគ្គនាយកដ្ឋាន នៃក្រសួង មាននាយកដ្ឋានចំណុះចំនួន ១២ ដូចតទៅ :

- នាយកដ្ឋាន កិច្ចការរដ្ឋបាល
- នាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការ ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស
- នាយកដ្ឋាន នីតិកម្មកសិកម្ម
- នាយកដ្ឋាន ភូគោលសាស្ត្រ និងកែលំអដីកសិកម្ម
- នាយកដ្ឋាន កសិ-ឧស្សាហកម្ម
- នាយកដ្ឋាន ផលិតកម្ម និង បសុពេទ្យាបាល
- នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
- នាយកដ្ឋាន គ្រឿងយន្តកសិកម្ម
- នាយកដ្ឋាន រុក្ខា-ប្រមាញ់
- នាយកដ្ឋាន ជលផល

- អគ្គនាយកដ្ឋានចំការកៅស៊ូ

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ២ ដូចតទៅ :

- នាយកដ្ឋាន អភិវឌ្ឍន៍ដំណាំកៅស៊ូ
- នាយកដ្ឋាន ទីផ្សារ និងសហប្រតិបត្តិការ

ខ-អង្គភាពថ្នាក់មូលដ្ឋាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង ។

គ-គ្រឹះស្ថានសាធារណៈ

អង្គភាពស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបច្ចុប្បន្ន កំពុងអនុវត្តជំនាញឯកទេសរបស់ខ្លួនរួមមាន :

- សកលវិទ្យាល័យភូមិន្ទកសិកម្ម
- វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- សាលាកសិកម្ម ព្រែកលៀប
- សាលាកសិកម្ម កំពង់ចាម
- ក្រុមហ៊ុនសំភារៈកសិកម្ម
- ក្រុមហ៊ុនអភិវឌ្ឍន៍កៅស៊ូកម្ពុជា
- វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- ក្រុមហ៊ុនដឹកជញ្ជូនអាហារណ នីហរណ និងសំភារៈបរិក្ខារកៅស៊ូ
- ក្រុមហ៊ុនចំការកៅស៊ូ មានចំនួន ៧គឺ : ក្រុមហ៊ុនចំការកៅស៊ូជប់ ក្រុមហ៊ុនចំការកៅស៊ូក្រែក ក្រុមហ៊ុនចំការកៅស៊ូមេមត់ ក្រុមហ៊ុនចំការកៅស៊ូស្នួល ក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូង ក្រុមហ៊ុនចំការកៅស៊ូបឹងកេត និងក្រុមហ៊ុនចំការកៅស៊ូពាមជាំង ។

អង្គការលេខ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូកទី ៣

## ខុទ្ទកាល័យ រដ្ឋមន្ត្រី

មាត្រា ៥ .-

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលបានកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យ លេខ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៤

## អគ្គាធិការដ្ឋាន

មាត្រា ៦ .-

អគ្គាធិការដ្ឋាន មានភារកិច្ច ធ្វើជាសេនាធិការអោយក្រសួង និងមានភារកិច្ច :

- ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយ និងពីមធ្យោបាយ កែលំអការប្រព្រឹត្តទៅ របស់អង្គភាពទាំងនោះ

- ប្រតិបត្តិភារកិច្ចផ្សេងៗទៀត ដែលរដ្ឋមន្ត្រីបានប្រគល់ជូន ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ៥

### អគ្គនាយកដ្ឋាននៃក្រសួង

មាត្រា ៧ .-

អគ្គនាយកដ្ឋាននៃក្រសួង មានភារកិច្ច ធ្វើជាសេនាធិការអោយលើការងារ:

- សំរបសំរួល និង តាមដានសកម្មភាពគ្រប់ផ្នែក របស់អង្គភាពថ្នាក់កណ្តាល អង្គភាពមូលដ្ឋានរបស់ក្រសួង និងគ្រឹះស្ថានសាធារណៈ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង និងជួយអោយបានសំរេចគោលដៅ ដែលបានកំណត់នៅក្នុង ក្របខ័ណ្ឌ នយោបាយអភិវឌ្ឍន៍កសិកម្ម

- ធ្វើអោយមានភាពស្របគ្នារវាងច្បាប់ទូទៅ និង លិខិតបទដ្ឋាន បទបញ្ជា ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដែលបាន រៀបចំ ឡើងដោយអង្គភាពចំណុះរបស់ក្រសួង

- សំរបសំរួលសកម្មភាពគ្រប់ផ្នែក ជាមួយអង្គភាពចំណុះក្រសួង និងជាមួយអង្គភាពផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹង ការងារ : រដ្ឋបាល បូកសរុប រាយការណ៍ ទុកដាក់ឯកសារ បុគ្គលិក ផែនការ ហិរញ្ញវត្ថុ និងសំភារៈបរិក្ខារ

- រៀបចំនិងកសាងនយោបាយយុទ្ធសាស្ត្រ ផែនការ និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួង ជាមួយបណ្តាក្រសួង ស្ថាប័ននានា និងធ្វើការងារសហប្រតិបត្តិការអន្តរជាតិ

- រៀបចំ និង តាក់តែងសេចក្តីព្រាងអត្ថបទច្បាប់និងបទបញ្ញត្តិផ្សេងៗដែលពាក់ពន្ធ័ទៅនឹងវិស័យកសិកម្ម

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

អគ្គនាយកដ្ឋាននៃក្រសួង ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋាននៃក្រសួងនេះ មាននាយកដ្ឋានចំណុះចំនួន ១២ ដូចមានក្នុងមាត្រាខាងក្រោម ។ នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា ៨ .-

នាយកដ្ឋាន កិច្ចការរដ្ឋបាល មានភារកិច្ច :

- សំរបសំរួលសកម្មភាពរដ្ឋបាលរបស់ក្រសួង នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលនឹងអង្គភាពមូលដ្ឋាន ចំណុះក្រសួង

- គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់ក្រសួង

- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ការពារសន្តិសុខ គ្រប់គ្រងការងារសង្គមរបស់ក្រសួង និងការងារពិធីការ

- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រង ប្រើប្រាស់ ជួសជុលយានយន្តសំភារៈ និងបរិក្ខាររបស់អង្គភាពអមទីស្តីការក្រសួង

- សរុប និង ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង

- តំកល់ឯកសារ

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ៩ --

នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ មានភារកិច្ច :

- ប្រមូលផ្តុំ និង សំរបសំរួល ជំពូកថវិកា
- លើកគំរោងថវិកាក្រសួង និង តាមដានរំលឹក ពីការ ប្រតិបត្តិ
- ទទួលខុសត្រូវថែរក្សាចញ្ជីកត់ត្រាគណនេយ្យទាំងឡាយ
- គ្រប់គ្រងបន្ទុកគណនី របស់ការអនុវត្តលទ្ធកម្មសាធារណៈ
- គ្រប់គ្រងពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- ប្រមូលផ្តុំតំរូវការ និង សំរបសំរួល រាល់ចំណាយរបស់ក្រសួង
- ប្រមូលចំណូលឱ្យបានសមស្រប តាមច្បាប់ហិរញ្ញវត្ថុ
- តាមដាន រំលឹក ការ គ្រប់គ្រងគណនីពិសេស
- គ្រប់គ្រង ចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និង ធ្វើបញ្ជីសារពើភ័ណ្ឌ
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពនានា ក្រោមឱវាទក្រសួង
- ធ្វើកិច្ចបញ្ជីការជាប្រចាំ នូវតារាងតុល្យការ និងគណនេយ្យរួបធាតុ
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រសួង
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

---

មាត្រា ១០ --

នាយកដ្ឋាន ផែនការ ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច :

- វិភាគ និងកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលខ្លី មធ្យម និងវែង និងតាមដានការអនុវត្ត

- ដឹកនាំអនុវត្តការអង្កេតទូទៅ ការអង្កេតតាមផ្នែករបស់វិស័យកសិកម្ម ប្រមូលព័ត៌មាន ស្ថិតិកសិកម្ម វិភាគវាយតំលៃនិងចងក្រងឯកសារ

- រៀបចំ កសាងនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម និងកំណត់គោលដៅ នៃការអភិវឌ្ឍន៍នោះ

- រៀបចំ កសាងកម្មវិធីវិនិយោគសាធារណៈ និងរៀបចំតំរង់ទិសកម្មវិធីវិនិយោគឯកជនក្នុងវិស័យកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍ គោលដៅអាហារូបត្ថម្ភ

- ស្រាវជ្រាវ និង ផ្សព្វផ្សាយអំពីថ្លៃកសិផល និងតំរូវការផលិតផលកសិកម្មគ្រប់ប្រភេទនៅទីផ្សារក្នុងស្រុក និង ទីផ្សារអន្តរជាតិ សំរាប់កសិករងាយស្រួលជ្រើសរើសធ្វើផលិតកម្មកសិកម្ម

- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារបច្ចេកទេសវិទ្យាសាស្ត្រកសិកម្ម

- ទំនាក់ទំនងសហការជាមួយស្ថាប័ននានា និងសហប្រតិបត្តិការជាមួយអន្តរជាតិ ក្នុងក្របខ័ណ្ឌការងារវិនិយោគ និងគំរោងផែនការ ដែលពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ១១ .-

នាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស មានភារកិច្ច :

- គ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

- រៀបចំលិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព

- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

- ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង

- រៀបចំការងារបៀវត្ស ពលកម្ម ប្រាក់កំរៃ និងរបបឧបត្ថម្ភ

- វាយតំលៃតំរូវការបណ្តុះបណ្តាលបុគ្គលិក និងពិនិត្យបញ្ជូនមន្ត្រីជំនាញទៅធ្វើកិក្រឹតការ ឬបន្តការសិក្សានៅក្នុង និងក្រៅប្រទេស

- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្ត ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ និងអនុវត្តនយោបាយនោះ

- សហការជាមួយបណ្តាអង្គភាព និងគ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្ម ដើម្បីចូលរួមកសាងកម្មវិធីសិក្សា និង សកម្មភាព របស់អង្គភាពទាំងនោះ សំរាប់បណ្តុះបណ្តាលអោយស្របទៅតាមតំរូវការអភិវឌ្ឍន៍នៃសង្គម

- លើកសំណើបង្កើត ឬរំលាយអង្គភាពនានា រៀបចំតួនាទីភារកិច្ច កែសំរួលរចនាសម្ព័ន្ធ តាមស្ថានភាពជាក់ស្តែង

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ១២ .-

នាយកដ្ឋាន នីតិកម្មកសិកម្ម មានភារកិច្ច :

- រៀបចំនយោបាយចំពោះកសិករ ជាអាទិ៍កសិករទន់ខ្សោយ ដើម្បីកែលំអស្ថានភាពសង្គមសេដ្ឋកិច្ច របស់គេនៅក្នុងសេដ្ឋកិច្ចទីផ្សារ

- រៀបចំល័ក្ខខ័ណ្ឌគតិយុត្តិនានា លើកវិធានការ និង បង្កលក្ខណៈងាយស្រួល ដល់ការអភិវឌ្ឍន៍អង្គភាព និង អង្គការកសិកម្ម

- ពាក់តែង និងពិនិត្យកែសំរួលសេចក្តីព្រាងអត្ថបទច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន តាមតំរូវការស្នើសុំពី នាយកដ្ឋាន នានា ឬពីអង្គភាពចំណុះក្រសួង អោយស្របតាមច្បាប់ជាធរមាន

- ផ្សព្វផ្សាយ និងតាមដានការអនុវត្ត អត្ថបទគតិយុត្តិ បទប្បញ្ញត្តិ លិខិតបទដ្ឋាន របស់វិស័យកសិកម្ម ដល់បណ្តា នាយកដ្ឋាន និង គ្រឹះស្ថានដែលពាក់ព័ន្ធ

- ចុះបញ្ជីការ កសាងបទមាណើយគុណភាពទៅតាមយថាប្រភេទ នៃសំភារៈកសិកម្ម និងពង្រឹកវិធានការ ត្រួតពិនិត្យ គុណភាពសំភារៈកសិកម្ម

- ជាអ្នកជំនួយការច្បាប់វិស័យកសិកម្ម សំរាប់ថ្នាក់ដឹកនាំក្រសួង និងបណ្តាអង្គភាពក្រោមអាណាព្យាបាល របស់ក្រសួង

- ទទួលភារកិច្ចផ្សេង១ទៀត ,ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ១៣ .-

នាយកដ្ឋាន ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម មានភារកិច្ច :

- រៀបចំនយោបាយ ផែនការ កម្មវិធី គំរោង និង វិធានការអភិវឌ្ឍន៍ ផលិតកម្មកសិកម្ម

- ចងក្រងសារពើភ័ណ្ឌដី និងបែងចែកប្រភេទដី

- តាមដានផលិតកម្មដំណាំផ្សេង១ វិភាគពីកត្តាបច្ចេកទេស ដែលពាក់ព័ន្ធទៅនឹងការផ្គត់ផ្គង់សំភារៈ ប្រើប្រាស់ក្នុងផលិតកម្ម ឬក្នុង ពាណិជ្ជកម្ម ដែលជះឥទ្ធិពលទៅលើការវិវត្ត នៃផលិតកម្មកសិកម្ម

- សំរបសំរួល រវាងអ្នកប្រតិបត្តិសាធារណៈ និងឯកជន និងប្រជាកសិករ ដើម្បីធ្វើអោយកាន់តែល្អនូវការ ផ្គត់ផ្គង់សំភារៈចាំបាច់សំរាប់ ផលិតកម្ម ដូចជាសេវាបច្ចេកទេស ឥណទាន ការផ្គត់ផ្គង់បណ្តាកត្តាផលិតកម្មនិងពាណិជ្ជកម្ម

- រៀបចំគំរោងអត្ថបទច្បាប់ និងបទបញ្ជា ស្តីពីគុណភាពផលិតផលកសិកម្ម ពីការប្រើប្រាស់កត្តា ផលិតកម្ម ពីការថែរក្សា និងការការពាររុក្ខជាតិតាមអនាម័យ និងរៀបចំលិខិតបទដ្ឋាន ទាក់ទងទៅនឹងផលិតកម្មដាំដុះ និង តាមដានការអនុវត្ត

- ផ្សព្វផ្សាយពត៌មានបច្ចេកវិទ្យា-សេដ្ឋកិច្ចកសិកម្ម ដល់ប្រជាកសិករ និងដល់ដៃគូខាងឧស្សាហកម្ម និងខាង ពាណិជ្ជកម្ម ដោយសហការគ្នាជាមួយស្ថាប័នសាធារណៈឯកទេស និង អង្គការកសិករ

- តាមដានស្ថានភាពសុខភាពដំណាំ ដើម្បីកំណត់វិធានការការពារ និងចាត់ចែងសកម្មភាពទប់ទល់ ប្រឆាំងនឹងកត្តាចង្រៃផ្សេង១

- ត្រួតពិនិត្យ គុណភាពសំភារៈប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម និង កំណត់វិធានការក្នុងការប្រើប្រាស់

- ត្រួតពិនិត្យ ភូតគាមអនាម័យនៅតាមព្រំដែន និងនៅតាមអង្គភាពកែច្នៃផលិតផលកសិកម្ម

- កំណត់គោលការណ៍ និងលិខិតបទដ្ឋានសំរាប់ការថែទាំដី ការប្រើប្រាស់ដីកសិកម្ម –និងការកែលំអដី ធ្វើអោយដីមានជីជាតិឡើងវិញ មានសុវត្ថិភាព និងទប់ទល់នឹងការហូរច្រោះដី

- រៀបចំគោលការណ៍ប្រើប្រាស់ដីទុកចោលទំនេរ ឬបានប្រើប្រាស់តិចតួច និងកំណត់បទដ្ឋានសំរាប់ដាក់អោយដាំដំណាំ និងតាមដាន ការអនុវត្ត

- ទទួលភារកិច្ចផ្សេង១ទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ១៤ --

នាយកដ្ឋាន កសិ-ឧស្សាហកម្ម មានភារកិច្ច :

- រៀបចំនយោបាយ ផែនការ កម្មវិធី គំរោង និងវិធានការអភិវឌ្ឍន៍ ដំណាំកសិ-ឧស្សាហកម្ម

- ចូលរួមដោះស្រាយរាល់បញ្ហា ដែលទាក់ទងដល់ការអភិវឌ្ឍន៍សហគ្រាសផ្នែកឧស្សាហកម្មកសិកម្ម និងម្ហូបអាហារ និងរៀបចំ កសាងនយោបាយកសិ-ឧស្សាហកម្ម ដើម្បីតំរង់ទិសការវិនិយោគផ្នែកផលិតកម្ម ផ្នែកកែច្នៃ និងផ្នែកពាណិជ្ជកម្ម

- ចូលរួមក្នុងការធ្វើទស្សនទាន និង បំផុសនយោបាយលើកកំពស់ដល់សហគ្រាសកសិ-ឧស្សាហកម្ម និងកសិ-ម្ហូបអាហារ

- ចូលរួមក្នុងការជំរុញ និង លើកកំពស់ ការវិនិយោគ ការនាំចេញផលិតផលកសិកម្ម និងម្ហូបអាហារ

- ផ្សព្វផ្សាយពត៌មានបច្ចេកវិទ្យា-សេដ្ឋកិច្ចកសិកម្ម ដល់អង្គការកសិករ និងដៃគូខាងឧស្សាហកម្ម និងខាងពាណិជ្ជកម្ម ដោយសហការគ្នាជាមួយស្ថាប័នសាធារណៈឯកទេស និងអង្គការកសិករ

- ទទួលភារកិច្ចផ្សេង១ទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា១៥ --

នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល មានភារកិច្ច :

- រៀបចំនយោបាយ ផែនការ កម្មវិធី គំរោង វិធានការអភិវឌ្ឍវិស័យផលិតកម្ម និងបសុព្យាបាល

- តាមដានសកម្មភាពផលិតកម្ម និងបសុព្យាបាល វិភាគពីកត្តាបច្ចេកទេស ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ និងការប្រើប្រាស់សំភារៈ ដែលជះឥទ្ធិពលទៅលើការវិវត្តរបស់វិស័យផលិតកម្មនិង បសុព្យាបាល

- សំរបសំរួល រវាងអ្នកប្រតិបត្តិសាធារណៈ និងឯកជន និងអ្នកចិញ្ចឹមសត្វ ដើម្បីធ្វើអោយកាន់តែល្អនូវការផ្គត់ផ្គង់ធាតុចាំបាច់ សំរាប់ផលិតកម្ម និងបសុព្យាបាល ដូចជាចំណេះបច្ចេកទេស ដល់ម្ចាស់ការផ្គត់ផ្គង់ចង្វាក់ផលិតកម្ម និង ពាណិជ្ជកម្ម

- រៀបចំ គំរោងអត្ថបទច្បាប់ និង បទបញ្ជា ស្តីពីគុណភាពផលិតផលចេញពីសត្វ ពីការថែរក្សា និងការការពារ ផ្នែកបសុព្យាបាល និងរៀបចំលិខិតបទដ្ឋាន ទាក់ទងទៅនឹងវិស័យផលិតកម្ម និងបសុព្យាបាល និងតាមដានការអនុវត្ត

- ផ្សព្វផ្សាយពត៌មាន បច្ចេកវិទ្យា-សេដ្ឋកិច្ចកសិកម្ម ដល់អ្នកចិញ្ចឹមសត្វ និង ដល់ដៃគូខាងឧស្សាហកម្ម និងខាង ពាណិជ្ជកម្ម ដោយសហការគ្នា ជាមួយស្ថាប័នសាធារណៈឯកទេស និងអង្គការកសិករ

- តាមដានស្ថានភាពសុខភាពសត្វ ដើម្បីកំណត់វិធានការការពារ និងចាត់ចែងសកម្មភាពប្រយុទ្ធប្រឆាំងនឹងភយ័ន្តរាយ ទាំងឡាយ

- ត្រួតពិនិត្យ គុណភាពសំភារៈប្រើប្រាស់ក្នុងវិស័យផលិតកម្ម និងបសុព្យាបាល និងកំណត់វិធានការក្នុងការប្រើប្រាស់

- ត្រួតពិនិត្យ ការនាំចេញ នាំចូលសត្វនៅតាមច្រកចេញ-ចូល និងត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រួតពិនិត្យនៅតាមទីសត្តឃាត និង នៅតាមទីកន្លែងកែច្នៃផលិតផលចេញពីសត្វ

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

## មាត្រា ១៦ --

នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម មានភារកិច្ច :

- រៀបចំ ជំរុញ និងសំរបសំរួលរាល់សកម្មភាពនៃការផ្សព្វផ្សាយ ការស្រាវជ្រាវ អភិវឌ្ឍន៍របស់ វិស័យកសិកម្ម ដោយទំនាក់ទំនងរវាងអង្គភាពជំនាញ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង មជ្ឈមណ្ឌល ស្រាវជ្រាវ ផលិតករ កសិករ និងអង្គការវិថ្វាជីវៈគ្រប់ជាន់ថ្នាក់

- តាមដានជាប្រចាំ សកម្មភាព និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ដោយផ្អែកលើព័ត៌មាន និង ប្រធានបទផ្តល់ចេញពីកសិករ និងពីអង្គភាពជំនាញ ហើយវាយតំលៃលទ្ធផលនៃការផ្សព្វផ្សាយ និង លើកវិធានការកែលំអវិធីសាស្ត្រផ្សព្វផ្សាយ

- កត់ត្រាជាប្រចាំ នូវចំណេះដឹងដែលទទួលបានពីកសិករ និងពីលទ្ធផលនៃការស្រាវជ្រាវបច្ចេកទេសវិស័យកសិកម្ម នៅក្នុង និងក្រៅប្រទេស ហើយធ្វើការផ្សព្វផ្សាយចំណេះដឹងទាំងនោះ ដល់ប្រជាកសិករ

- ប្រមូល និងសំរាំងចំណេះដឹងរបស់កសិករ និងលទ្ធផលស្រាវជ្រាវរកឃើញថ្មី នៅក្នុង និង ក្រៅប្រទេស ហើយធ្វើការផ្សព្វផ្សាយ និងបំពាក់បំប៉នដល់ប្រជាកសិករ អំពីការរកឃើញថ្មីទាំងនោះ

- បង្កើត និងរក្សាទំនាក់ទំនងផ្ទាល់ រវាងអ្នកស្រាវជ្រាវក្សេត្រវិទ្យា ឬជំនាញផ្សេងៗដទៃទៀតក្នុងវិស័យកសិកម្ម ជាមួយនឹងកសិករ អ្នកចិញ្ចឹមសត្វ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង ដើម្បីបង្កើនការផ្លាស់ប្តូរព័ត៌មាននិងចំណេះដឹងបច្ចេកទេសរវាងគ្នានិងគ្នា ដែលធ្វើអោយមានការស៊ីសង្វាក់គ្នា ហើយឆ្លើយតបរវាងការស្រាវជ្រាវ និងផលិតកម្ម ទៅនឹងតំរូវការនៃការអភិវឌ្ឍវិស័យកសិកម្ម

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

## មាត្រា ១៧ --

នាយកដ្ឋាន គ្រឿងយន្តកសិកម្ម មានភារកិច្ច :

- ស្រាវជ្រាវ និងកំណត់បែងចែកតំបន់ប្រើប្រាស់គ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម ម៉ាស៊ីនកសិកម្ម តាមប្រភេទដី និងតាមមុខដំណាំ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម

- រៀបចំគោលការណ៍ លិខិតបទដ្ឋាន អំពីសត្តានុពល និងអំពីប្រសិទ្ធភាពគ្រឿងយន្តកសិកម្មក្នុងផលិតកម្មដាំដុះ

- ស្រាវជ្រាវ និងផ្តួចផ្តើមគំនិត ផលិតឧបករណ៍កសិកម្ម ដើម្បីបន្ថយការប្រើប្រាស់កម្លាំងពលកម្មមនុស្សក្នុង ការងារផលិតកម្មកសិកម្ម

- ណែនាំ និងផ្សព្វផ្សាយបច្ចេកទេស ដល់អ្នកប្រើប្រាស់គ្រឿងយន្តកសិកម្ម ដើម្បីកែលំអផលិតកម្ម និងផលិតភាព កសិកម្ម

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ១៨ --

នាយកដ្ឋាន វុក្ខា-ប្រមាញ់ មានភារកិច្ច :

- ធ្វើបញ្ជីសារពើភ័ណ្ឌធនធានព្រៃឈើ និងសត្វព្រៃ វាយតំលៃសក្តានុពលភាព ការបែងចែកប្រភេទ និងតាមដាន ការវិវឌ្ឍន៍របស់ព្រៃឈើ និងសត្វព្រៃ

- រៀបចំគំរោង អត្ថបទច្បាប់ លិខិតបទដ្ឋាន បទបញ្ជា សំរាប់ការពារ និងសំរាប់គ្រប់គ្រងការធ្វើអាជីវកម្មធនធានព្រៃឈើ ការអភិរក្សសត្វព្រៃ ការប្រមាញ់ និងត្រួតពិនិត្យការអនុវត្ត

- ចូលរួមកំណត់វិធានការរក្សាការពារបរិស្ថាន និងរៀបចំកសាងផែនការ គ្រប់គ្រងដែនដីព្រៃឈើ ទីព្រៃបំរុងទុកសំរាប់ធ្វើជំរកសត្វព្រៃ តំបន់ការពារធម្មជាតិ តំបន់ដាំព្រៃឈើឡើងវិញ និងកំណត់នយោបាយអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ

- ធ្វើការសិក្សាស្រាវជ្រាវ អំពីវិទ្យាសាស្ត្រវិស័យព្រៃឈើ និងសត្វព្រៃ និងចងក្រងឯកសារ

- ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាពធ្វើអាជីវកម្មផល អនុផលព្រៃឈើ និងរាល់សកម្មភាពធ្វើប្រមាញ់ ធនធានសត្វព្រៃ

- ជួយទំនុកបំរុង លើកទឹកចិត្ត អ្នកផ្តើមគំនិតការពារ និងធ្វើអោយកកើតឡើងវិញ នូវធនធានព្រៃឈើ និងសត្វព្រៃ ហើយនិងយកចិត្តទុកដាក់ដល់សហគមន៍ព្រៃឈើ

- គ្រប់គ្រង និងអភិវឌ្ឍន៍សួនសត្វ

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ១៩ --

នាយកដ្ឋាន ជលផល មានភារកិច្ច :

- ធ្វើបញ្ជីសារពើភ័ណ្ឌធនធានជលផល វាយតំលៃសក្តានុពលភាព ការបែងចែកប្រភេទ និងតាមដានការវិវត្តរបស់ ធនធានជលផល និងវារីវប្បកម្ម

- រៀបចំគំរោង អត្ថបទច្បាប់ លិខិតបទដ្ឋាន បទបញ្ជា សំរាប់ការពារ ថែរក្សា កែលំអ និងពង្រឹងសណ្តាប់ធ្នាប់ ដែននេសាទ និងសំរាប់គ្រប់គ្រងការធ្វើអាជីវកម្មធនធានជលផល ទាំងផ្នែកទឹកសាប និងដែនសមុទ្រ និងត្រួតពិនិត្យការអនុវត្ត

- ចូលរួមកំណត់វិធានការរក្សាការពារបរិស្ថាន និងរៀបចំកសាងផែនការ គ្រប់គ្រងដែននេសាទ កន្លែងនេសាទបំរុងទុក និងកំណត់នយោបាយអភិវឌ្ឍន៍ និងអភិរក្ស ធនធានជលផល

- ធ្វើការសិក្សាស្រាវជ្រាវ អំពីវិទ្យាសាស្ត្រវិស័យជលផល និងវារីវប្បកម្ម និងចងក្រងឯកសារ

- ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាពធ្វើអាជីវកម្មធនធានជលផល និងវារីវប្បកម្ម

- ជួយទំនុកបំរុង លើកទឹកចិត្ត ដល់អ្នកផ្តើមគំនិតការពារ និងធ្វើអោយកកើតឡើងវិញ នូវធនធានជលផល និងយកចិត្តទុកដាក់ ជំរុញវារីវប្បកម្ម

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

## ជំពូកទី ៦

### អគ្គនាយកដ្ឋានចំការកៅស៊ូ

មាត្រា ២០ .-

អគ្គនាយកដ្ឋាន ចំការកៅស៊ូ មានភារកិច្ច ធ្វើជាសេនាធិការអោយលើការងារ:

- សិក្សា និងរៀបចំគោលនយោបាយអភិវឌ្ឍន៍ដីក្រហម និងដីប្រភេទផ្សេងៗទៀត ដែលអាចដាំដំណាំកៅស៊ូបាន និងតាមដានការវិវត្តវិស័យកៅស៊ូកម្ពុជា
- រៀបចំប្រព័ន្ធឯកសារ ស្ថិតិ លើដំណាំកៅស៊ូ
- សិក្សា និងផ្សព្វផ្សាយអំពីថ្លៃកៅស៊ូ និងតំរូវការកៅស៊ូធម្មជាតិ លើទីផ្សារជាតិ និងអន្តរជាតិ សំរាប់ជំរុញនិងលើកទឹកចិត្ត ដល់អ្នកដាំកៅស៊ូគ្រួសារ
- ធ្វើសហប្រតិបត្តិការជាមួយអន្តរជាតិ ដើម្បីជំរុញ និងអភិវឌ្ឍន៍ដីក្រហម និងដីប្រភេទផ្សេងៗទៀត ដែលអាចដាំដំណាំកៅស៊ូបាន
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

អគ្គនាយកដ្ឋានចំការកៅស៊ូ ដឹកនាំដោយអគ្គនាយកមួយរូបនិង អមដោយអគ្គនាយករងជាជំនួយការ ។

អគ្គនាយកដ្ឋាន នេះមាននាយកដ្ឋានចំណុះចំនួន ២ ដូចមានក្នុងមាត្រាខាងក្រោម ។ នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

មាត្រា ២១ .-

នាយកដ្ឋាន អភិវឌ្ឍន៍ដំណាំកៅស៊ូ មានភារកិច្ច:

- កសាងគំរោងផែនការអភិវឌ្ឍ និងស្រាវជ្រាវ អំពីលក្ខណសម្បត្តិធម្មជាតិដីក្រហម និងដីប្រភេទផ្សេងៗទៀត ដែលអាចដាំដំណាំកៅស៊ូបាន
- សិក្សា និងផ្សព្វផ្សាយឲ្យបាច់នានា ដើម្បីទាក់ទាញវិនិយោគិនអោយចូលរួមអភិវឌ្ឍន៍វិស័យកៅស៊ូ
- សហការជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ និងបណ្តាក្រុមហ៊ុនចំការកៅស៊ូ និងជាមួយអន្តរជាតិ ដើម្បីជំរុញ និងអភិវឌ្ឍន៍វិស័យកៅស៊ូ
- ទទួលភារកិច្ចផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មាត្រា ២២ .-

នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការ មានភារកិច្ច:

- ផ្សព្វផ្សាយពត៌មានបច្ចេកវិទ្យា-សេដ្ឋកិច្ចវិស័យកៅស៊ូ ដល់វិនិយោគិន ដល់អ្នកដាំកៅស៊ូគ្រួសារដល់ផែនខាងឧស្សាហកម្ម ឬខាងពាណិជ្ជកម្ម ដោយសហការជាមួយស្ថាប័នសាធារណៈឯកទេស និងសមាគមអ្នកដាំកៅស៊ូ
- សិក្សា និងផ្សព្វផ្សាយ អំពីតំរូវការ និងអំពីថ្លៃកៅស៊ូ នៅលើទីផ្សារជាតិ និងអន្តរជាតិ
- តាមដានការអនុវត្ត និងវាយតំលៃលទ្ធផល ក្នុងវិស័យកៅស៊ូ និងក្នុងវិស័យកែច្នៃផលិតផលចេញពីកៅស៊ូ
- ទទួលភារកិច្ចផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

## ជំពូកទី ៧

### អង្គភាពមូលដ្ឋាន

មាត្រា ២៣ .-

នៅតាមខេត្ត ក្រុងនីមួយៗ មានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង ដែលទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាព របស់ក្រសួង ។

## ជំពូកទី ៨

### គ្រឹះស្ថានសាធារណៈ

មាត្រា ២៤ .-

អង្គភាពដែលស្ថិតនៅមាត្រា ៤ ចំណុច គ ត្រូវបាននិងត្រូវរៀបចំ អោយទៅជាគ្រឹះស្ថានសាធារណៈ ឧបនិស្ស័យរដ្ឋបាល ឬសហគ្រាសសាធារណៈ ក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានសាធារណៈ ឬសហគ្រាសសាធារណៈនីមួយៗនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ដែលមានលក្ខន្តិកៈមួយដោយឡែករបស់ខ្លួន ដោយអនុវត្តស្របតាមព្រះរាជក្រមលេខ ជស / រកម / ០៦៩៦ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលហលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងព្រះរាជក្រឹត្យលេខ នស/ រកត/ ១២៩៧/ ៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីសហលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

## ជំពូកទី ៩

### អង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ

មាត្រា ២៥ .-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌ នៃបទបញ្ញា កំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា ក្នុងពណ្ឌក្រសួង ។

## ជំពូកទី ១០

### អវសានប្បញ្ញត្តិ

មាត្រា ២៦ .-

ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងនេះរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២៧ .-

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ននៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការគ្នាដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានស្ថាប័នទាំងនោះ ។

មាត្រា ២៨ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣០ .-

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន ៖
សម្ដេចនាយករដ្ឋមន្ត្រី
ដើម្បី សុំចុះហត្ថលេខា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

ចាន់ សារុន

កន្លែងទទួល៖
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្ដាល
- គ្រប់សាលា ខេត្ត-ក្រុង
- ដូចមាត្រា ២៩
- ឯកសារ - កាលប្បវត្តិ

មាត្រា ២៧ .-

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ននៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការគ្នាដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានស្ថាប័នទាំងនោះ ។

មាត្រា ២៨ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣០ .-

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០០

ឈឹម សុខ

បានជំរាបជូន :
សម្តេចនាយករដ្ឋមន្ត្រី
ដើម្បី សុំចុះហត្ថលេខា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

ឈា សុខ

<u>កន្លែងទទួល:</u>
-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលា ខេត្ត-ក្រុង
-ដូចមាត្រា ២៩
-ឯកសារ - កាលប្បវត្តិ

លេខ : 133 ចល.កសក
បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក :
-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង
ដើម្បីជ្រាបនិងអនុវត្ត
ភ្នំពេញ ថ្ងៃទី 25 ខែ មេសា ឆ្នាំ ២០០០
ក.ប.រដ្ឋមន្ត្រី
អគ្គនាយក

គ្រុំ_សារ៉ុន

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ១៧ អនក្រ.បក

ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០

# អង្គការលេខ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

